ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៦៦១៥ អយក-ប្រក

# ប្រកាស
## ស្តីពីការបើកសាលាបឋមសិក្សា ឃ្លាំងមឿង
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតស្នើសុំរបស់គណៈកម្មការសាងសង់សាលាបឋមសិក្សា ឃ្លាំងមឿង ចុះថ្ងៃទី ០៥ មិថុនា ឆ្នាំ ២០០២ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត តាកែវ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០២ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សម្រេច

**ប្រការ១** :- បើកសាលាបឋមសិក្សា **ឃ្លាំងមឿង** ដែលមានទីតាំងស្ថិតនៅ ឃុំ **ធំសរ** ស្រុក **បាទី** ខេត្ត **តាកែវ** ជាសាលាបឋមសិក្សា ពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **ឃ្លាំងមឿង** ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :- នាយក នាយករង មានសិទ្ធទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **បាទី** នាយកសាលាបឋមសិក្សា **ឃ្លាំងមឿង** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

ទ្រឹម.សិដ្ឋិ

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាបជាពត៌មាន "

- សាលាខេត្ត តាកែវ

" ជូនជ្រាបជាពត៌មាន "

- ដូចប្រការ ៥
- កាលប្បវត្តិ - ឯកសារ នា.បម